ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សមិទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

អនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គភាពជំនាញក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនដែលបានកំណត់យ៉ាងច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពដែលត្រូវអនុវត្តតាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មទៅតាមអភិក្រមក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្មតាមផ្នែកអាទិភាពនីមួយៗ និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

សម្រាប់ឆ្នាំ២០១៥នេះ ការងារប្រមូលផលស្រូវរដូវវស្សាត្រូវបានវាយតម្លៃថាអនុវត្តលឿនជាងឆ្នាំមុន ដែលមកទល់ពេលនេះការប្រមូលផលសម្រេចបានប្រមាណ៨៩,៣០% (ឆ្នាំមុនសម្រេចបានតែ៨៨,៦២%ប៉ុណ្ណោះ)។ ខេត្តចំនួន១០ គឺខេត្តកោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ កែប ប៉ៃលិន និងត្បូងឃ្មុំ បានបញ្ចប់ការប្រមូលផលស្រូវរដូវវស្សារួចរាល់ហើយ។ ដោយឡែក ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ ទោះបីជួបប្រទះឥទ្ធិពលអវិជ្ជមានបណ្តាលមកពីគ្រោះរាំងស្ងួតកាលពីរដូវវស្សាយ៉ាងណាក៏ដោយ ក៏ការដាំដុះសម្រេចបានចំនួន៤១៩.៥៩៥ ហិកតា ស្មើនឹង១០០,៥៤% នៃផែនការ៤១៧.៣២៥ហិកតា លឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យខិតខំថែទាំដំណាំស្រូវរដូវប្រាំង ដោយយកចិត្តទុកដាក់ ការគ្រប់គ្រងនិងថែរក្សាទឹកទុកឲ្យបានគត់មត់ ក៏ដូចជាការថែទាំដំណាំផ្សេងៗ ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់ពីលទ្ធភាពនៅកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកិច្ចប្រជុំមួយដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីវាយតម្លៃ និងបូកសរុបលទ្ធផលបឋមនៃការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ និងវិធានការជំរុញការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានសម្រាប់ឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៤៧៨.៦៤៨ហិកតា លើសឆ្នាំមុនចំនួន១៦.១២៨ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន១៥.៣៤៩ហិកតា ស្មើនឹង៣,២១% និងគ្រឿងយន្តចំនួន៤៦៣,២៩៩ហិកតា ស្មើនឹង៩៦,៧៩%



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

- ផ្ទៃដីសាបសម្រេចបានចំនួន១.១៣១ហិកតា តិចជាងឆ្នាំមុនចំនួន២.៦៦០ហិកតា

- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៤១៩.៥៩៥ហិកតា ស្មើនឹង១០០,៥៤% នៃផែនការ៤១៧.៣២៥ហិកតា លើសឆ្នាំមុនចំនួន២៦.៦៦២ហិកតា។

### ១.២ ល្បឿនការងារប្រមូលផលស្រូវវស្សាឆ្នាំ២០១៥

ផ្ទៃដីអនុវត្តសរុបចំនួន២.៥៦១.៩៥៧ហិកតា ស្មើនឹង៩៩,៨០% នៃផែនការ២.៥៦៧.១៣០ហិកតា តិចជាងឆ្នាំមុនចំនួន២.៦១៥ហិកតា ក្នុងនោះ ការងារប្រមូលផលស្រូវសម្រេចបានលើផ្ទៃដីចំនួន២.២៨០.៩៤៦ហិកតា លើសឆ្នាំមុន៨.៣២៤ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៦.២៤៩.៤០៩តោន តិចជាងឆ្នាំមុន១០.៤០០តោន និងទិន្នផលជាមធ្យមចំនួន២,៧៤០តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន១៥គីឡូក្រាមក្នុងមួយហិកតា។

### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៤០.៩១២ហិកតា ស្មើនឹង៩៥,៨២% នៃផែនការ៤២.៦៩៨ហិកតា តិចជាងឆ្នាំមុនចំនួន៣.៣២៥ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន៧.៩០៥ហិកតា ស្មើនឹង៣៨,៨៨%នៃផែនការ២០.៣៣១ហិកតា តិចជាងឆ្នាំមុនចំនួន២.៩៤១ហិកតា។

### ១.៤ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាសម្រាប់ឆ្នាំ២០១៥នេះ មានបរិមាណចំនួន៥៣៨.៣៩៦តោន ដែលមានការកើនឡើងចំនួន១៥១.៣៣៥តោន(+៣៩,១%) លើសបរិមាណនាំចេញក្នុងឆ្នាំ២០១៤ ដែលមានតែ៣៨៧.០៦១តោន។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៥នេះ មានបរិមាណរហូតដល់៨១.៤៧៩តោន ដែលមានការកើនឡើងចំនួន៣០.៣៤៣តោន(+៥៩,៣%) លើសបរិមាណនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៤ ដែលមានតែ៥១.១៣៦តោន និងនាំចេញទៅកាន់ទិសដៅចំនួន៦០ប្រទេស។

### ១.៥ ការវាយតម្លៃ និងបូកសរុបលទ្ធផលប៉ាន់ស្មានជំហានដំបូងលើការងារបង្កបង្កើនផលស្រូវឆ្នាំ២០១៥-២០១៦

តាមរយៈការបូកសរុបបឋម លទ្ធផលប៉ាន់ស្មានជំហានដំបូងលើការងារបង្កបង្កើនផលស្រូវឆ្នាំ២០១៥-២០១៦ នឹងអាចសម្រេចបានលើផ្ទៃដីបង្កបង្កើនផលចំនួន៣.០២៧.១២៤ហិកតា(រដូវវស្សា២.៥៦១.៩៥៧ហិកតា+រដូវប្រាំង៤៦៥.១៦៧ហិកតា=៣.០២៧,១២៤ហិកតា) គឺតិចជាងឆ្នាំមុនចំនួន២៨.៣៨៣ហិកតា (ឆ្នាំមុនអនុវត្តបានចំនួន៣.០៥៥.៥០៧ហិកតា)។ ផ្ទៃដីប្រមូលផលសរុបអាចទទួលបានចំនួន២.៩៩៦.២៥៩ហិកតា(រដូវវស្សា២.៥៣៦.១៩៧ហិកតា+រដូវប្រាំង៥៦០.០៦២ហិកតា=២.៩៩៦.២៥៩ហិកតា) គឺតិចជាងឆ្នាំមុនចំនួន៣២.៥៧៧ហិកតា (ឆ្នាំមុន៣,០២៨លានហិកតា)។ បរិមាណផលប៉ាន់ស្មានសរុប៩.២២៧.០២១តោន (ឆ្នាំមុន៩,៣២លានតោន) និងទិន្នផលមធ្យមទូទាំងប្រទេស៣,០៨០តោន/ហិកតា (ឆ្នាំមុន៣,០៧៩តោន/ហិកតា)។ ដូច្នេះបើគិតពីតុល្យភាពស្បៀងរវាងសេចក្តីត្រូវការ និងបរិមាណផលស្រូវទទួលបានឃើញថា អាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង៤,៥លានតោន (ឆ្នាំមុនសម្រេចបាន៤,៧លានតោន) និងគិតជាអង្ករប្រមាណជាង២,៩១លានតោន (ឆ្នាំមុនជាង៣,០១លានតោន) សម្រាប់នាំចេញ។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារធនាគមនិងផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៧,៥១ | ៧៥៧,១៦ | ២៤៩,៦៥ | ៣៨០,៧៣ |
| សរុប I | | ៥០៧,៥១ | ៧៥៧,១៦ | ២៤៩,៦៥ | ៣៨០,៧៣ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨,៣៧ | ១៦.០២៧,៨១ | ៤.៤០៩,៤៤ | ១៦.១៩០,២៣ |

| | | | | | |
|---|---|---|---|---|---|
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.៤៩៨,០៦ | ២.៤១៩,៥៣ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៨៩,៥៧ | ២.០៤៦,៦៩ | ១.០៥៧,១២ | ១.០៤៩,០២ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៦៤៥,៩៧ | ៥.៧១១,៣៥ | ៣.០៦៥,៣៨ | ៦.៥៨៦,០១ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៨.៦៦១,៤០ | ៥.៣៩២,៦៦ | ២.៩០៥,២២ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសេសស៍ (ស្នួល) | ១.៧៤៤,៧៨ | ៤.៣៦៥,៣០ | ២.៦២០,៥២ | ២.១២៧,២៧ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង,រមាសហែក) | ១.៨៨១,៧៩ | ៣.៣៩០,១៩ | ១.៥០៨,៤០ | ១.១៧៧,៣១ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.៣២៧,២០ | ៥.៩២៤,៥០ | ២.៥៩៧,៣០ | ១.៥៤៩,៩៦ |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦,០៩ | ៥.៧៣១,៤៧ | ២.៤៧៥,៣៨ | ៤.៦៩៦,៣៦ |
| សរុប II | | ២៨.៨១១,០៤ | ៥៤.៣៥៦,៧៧ | ២៥.៥៤៥,៧៣ | ៣៦.២៨១,៣៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៦១.៦៧៧,០០ | ១៥៥.២៦២,០០ | ៥.១៣២,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ១៤០.៣៤៦,០០ | ៦៦.៩៥០,០០ | ៧៨.៩០១,០០ |
| សរុប III | | ៧៩.៨១១,០០ | ៣០២.០២៣,០០ | ២២២.២១២,០០ | ៨៤.០៣៣,០០ |
| សរុប I+II+III | | ១០៩.១២៩,៥៥ | ៣៥៧.១៣៦,៩៣ | ២៤៨.០០៧,៣៨ | ១២០.៦៩៥,១១ |

- គួរកត់សម្គាល់ថា សម្រាប់ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.០៨១ដុល្លារក្នុងមួយតោន។
- ព្រឹត្តការណ៍សំខាន់មួយទៀតគឺ ក្រសួងបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៥ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៥ ដែលមានសមាជិកចូលរួមប្រមាណជាង៣០០នាក់ ក្នុងនោះភ្ញៀវអន្តរជាតិមកពី១៣ប្រទេស។ កិច្ចប្រជុំបានប្រព្រឹត្តទៅប្រកបដោយភាពរលូន និងជោគជ័យ អាស្រ័យដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាល និងដោយមានការចូលរួមគាំទ្រយ៉ាងសកម្មពីបណ្តាប្រទេសជាសមាជិកពីលេខាធិការដ្ឋាន ANRPC និងពីប្រតិបត្តិករកៅស៊ូនានារួមមាន៖ អ្នកដាំដុះ ពាណិជ្ជករ សេដ្ឋវិទូ និងកម្មន្តសាលករ។

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- សហការជាមួយ CIRAD រៀបចំសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាដើម្បីអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជា
- ចុះបេសកកម្មតាមបណ្តាខេត្តដែលមានចម្ការកៅស៊ូ ដើម្បីចូលរួមសហការរាល់ការងារដែលពាក់ព័ន្ធនឹងបច្ចេកទេសកៅស៊ូ
- ធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកបានចំនួន៤លើកដើម្បីវាយតម្លៃសមត្ថភាពសម្រាប់ការទទួលស្គាល់ជាផ្លូវការពីវិទ្យាស្ថាន
- ចូលរួមជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន និងពីសាកលវិទ្យាល័យ Hawaii ប្រទេសអាមេរិក ដើម្បីជួសជុលនិងថែទាំឧបករណ៍ Flux Tower និង Sap flow នៅស្ថានីយអនុវត្តនៃវិទ្យាស្ថាន
- ចូលរួមការងារជាមួយជំនាញអង្គការ UNIDO ដើម្បីរៀបចំសៀវភៅសម្រាប់ការទទួលស្គាល់ការធ្វើតេស្ត និងការបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍ជាតិយថាប្រភេទ
- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់កសិករបានចំនួន៨វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន២១៣នាក់
- បន្តបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកល វិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម សាលាជាតិកសិកម្មព្រែកលៀប និងសាកលវិទ្យាល័យស្វាយរៀង។

# ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជា

លក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត ការរៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- ការងារកែលម្អពូជ៖ ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

- ការងារឡជីវឧស្ម័ន៖ ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១.៨៥៩ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបានក្នុងឆ្នាំ២០១៥ចំនួន២៥០ឡ។

- ចំណីសត្វ៖ បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- ការងារដំណាំចំណីសត្វ៖ តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថ-ប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

៣.២ ការងារបសុព្យាបាល

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ខេត្ត-រាជធានីចំនួន២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន៣៥.៦២៣លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយបានកប់និងកម្ទេចចោលផលិតផលសាច់ខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន២.១៧៦,៥គីឡូក្រាម ចាប់មាន់រស់លួចនាំចូលចំនួន៣ករណី ស្មើនឹងចំនួន១.៦៤០ក្បាល បង្ក្រាបបទល្មើសចំនួន២២៥ករណីនិងពិន័យជាទឹកប្រាក់ចំនួន៥៨លានរៀល និងបំផ្លាញសត្វទាដែលមានផ្ទុកជំងឺផ្តាសាយបក្សីចំនួន៣.០០០ក្បាល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង និងបង្ក្រាបបទល្មើសអាជីវកម្មខុសច្បាប់ចំនួន១២ករណី។

- ការងារសុខភាពសាធារណៈ៖ ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានជាប្រចាំឱ្យស្របតាមលក្ខណៈបច្ចេកទេស។

- ការងារនីតិកម្មនិងវិវាទ៖ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានរដ្ឋសភាពិនិត្យនិងអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ និងបានបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យនិងអនុម័តនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦នេះ។

៣.៣ ការងារស្រាវជ្រាវ៖

- ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន១៦២ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៣ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤៨ក្បាល គោកំផែងសែន៤៤ក្បាល និងគោកើតថ្មី១៦ក្បាល គោលក់ចំនួន៦ក្បាល និងគោងាប់ចំនួន៤ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប១៧៦ក្បាល ក្នុងនោះជ្រូកបាចំនួន៤ក្បាល ជ្រូកមេ៦៨ក្បាល កូនជ្រូក៨៥ក្បាល មេបាជ្រូកលក់ចំនួន៨ក្បាល កូនជ្រូកលក់៦០៩ក្បាល កូនជ្រូកងាប់ចំនួន៨ក្បាល និងកូនជ្រូកទុកបម្រុងចំនួន១៩ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

• ការងារស្រាវជ្រាវបសុព្យាបាលៈ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងឆ្នាំ២០១៥នេះ ពិនិត្យវត្ថុវិភាគសរុបចំនួន៣.៧៣៧ករណី។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែករុក្ខាប្រមាញ់ឈើ

### ៤.១ ការងាររុក្ខាប្រមាញ់ឈើ

- កំណត់ព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ប្រចាំឆ្នាំ២០១៥ អនុវត្តក្នុងដែនសមត្ថកិច្ចខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ បានបោះបង្គោលសរុបចំនួន១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំបានចំនួន១១២បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើក្រចេះបានចំនួន១៧៥បង្គោល ខណ្ឌរដ្ឋបាលព្រៃឈើកោះកុងបានចំនួន១៧៥បង្គោល

- លើកគម្រោងថវិកាបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០១៦ (P3&P4) ក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន៤ រួមមាន ខណ្ឌរដ្ឋបាលព្រៃឈើកំពត ពោធិ៍សាត់ មណ្ឌលគិរី និងព្រៃវែង លើផ្ទៃដីប្រវែង៨២គីឡូម៉ែត្រ

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងកសាងផែនទីកាបូនព្រៃឈើ សហការជាមួយអ្នកជំនាញការជប៉ុនពី Forest and Forest Products Research Institute (FFPRI)

- រៀបចំរបាយការណ៍ប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើថ្នាក់ជាតិ និងឯកសារកម្រិតបំភាយយោងការបញ្ចេញឧស្ម័នកាបូនិចពីការបាត់បង់ព្រៃឈើ ដើម្បីចូលរួមសន្និសីទនៃរដ្ឋភាគីលើកទី២១ ក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅទីក្រុងប៉ារីស ប្រទេសបារាំង ដោយមានកិច្ចសហការបច្ចេកទេសពីអ្នកជំនាញការ JICA, CAM-REDD និង FAO

- បានចេញប្រកាសស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន៤០សហគមន៍ព្រៃឈើ គ្របដណ្តប់លើផ្ទៃដីទំហំសរុប១១.៦៩៥ហិកតា នៅក្នុងខេត្តស្វាយរៀង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន២៨សហគមន៍ លើផ្ទៃដីទំហំ២៣.៥៣៦ហិកតា នៅខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តរតនគិរី និងខេត្តពោធិ៍សាត់

- ពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន៥០ នៅខេត្តស្ទឹងត្រែង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តក្រចេះ។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- ពិគ្រោះយោបល់ចំនួន៥លើក លើការងារបង្កើតព្រៃការពារព្រៃឡង់ និងព្រៃការពារសៀមប៉ាង ជាមួយអាជ្ញាធរភូមិ ឃុំ ប្រធានសហគមន៍ព្រៃឈើ និងសមាជិកសហគមន៍សំខាន់ៗ នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ,ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និងស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលទំហំតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង និងរៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ ព្រះរការ ដែលមានទំហំ៩២,១៣២ហិកតា ក្នុងខេត្តព្រះវិហារ

- តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម តំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប និងតំបន់ព្រៃការពារព្រះវិហារ បានទទួលភ្ញៀវទេសចរណ៍បរទេសមកទស្សនាចំនួន១.០៥៦នាក់

- ចុះកំណត់តំបន់សក្តានុពលសម្រាប់បង្កើតជាតំបន់ទេសចរណ៍ធម្មជាតិនៅក្នុងព្រៃការពារសីមា។ នៅក្នុងការពិភាក្សា ប្រជាពលរដ្ឋ និងអាជ្ញាធរឃុំបានបញ្ជាក់ថា តំបន់ព្រៃការពារសីមាមានសក្តានុពលសម្រាប់រៀបចំជាតំបន់ទេសចរណ៍ធម្មជាតិ

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំឆ្នាំនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ក្នុងនោះសត្វស្លាបចំនួន២០៣ប្រភេទ ត្រូវបានធ្វើការកត់ត្រា

- ចុះប្រមូលសំណាកសត្វប្រចៀវ និងជ្រូងសរុបចំនួន១.១១២សំណាក (សត្វជ្រូងចំនួន១៥៨សំណាក) ដើម្បីធ្វើការពិនិត្យទៅលើការបន្តពូជ ការកំណត់អត្តសញ្ញាណ និងការវិភាគរកមេរោគ និងប្រមូលសំណាកសត្វព្រៃបានចំនួន ២.៥៦៣សំណាក ដើម្បីធ្វើការវិភាគរកជំងឺដែលមានប្រភពពីសត្វព្រៃ

- ផ្តល់ចំណីដល់សត្វត្មាតនៅខេត្តស្ទឹងត្រែង-ក្រចេះ ព្រៃការពារព្រះវិហារ ព្រៃការពារសៀមប៉ាង និងព្រៃការពារមណ្ឌលគិរី ដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការអង្កេតតាមដាន ដោយរាប់ឃើញត្មាតសរុបចំនួន២៣៥ក្បាល

- ធ្វើការការពារសំបុកសត្វត្រយ៉ងចង្កំកសចំនួន៦២សម្បុក ត្រដក់តូចចំនួន១៦៨សម្បុក រំពេទន្លេចំនួន១៨សម្បុក ត្មាតចំនួន៣១សម្បុក ត្រយ៉ងយក្សចំនួន២៧សម្បុក នៅខេត្តស្ទឹងត្រែង-ក្រចេះ ព្រៃការពារសៀមប៉ាង និងព្រៃការពារព្រះវិហារ។ ការពារសំបុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសំបុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ

- ចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋដែលទទួលរងការបំផ្លាញដំណាំពីសត្វដំរីព្រៃ និងបាននាំយកកាំជ្រួចចំនួន ១.៩៥០ដើម ពិលបង្កើលដំរីចំនួន១៤ដើម ប្រេងម៉ាស៊ូតចំនួន៣០លីត្រ សាំងចំនួន២លីត្រ ចែកជូនដល់គ្រួសារដែលរងនូវការបំផ្លាញដំណាំដើម្បីទុកសម្រាប់ប្រើប្រាស់ពេលដំរីចូលចម្ការ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១.៣១៧ក្បាល សត្វកើតថ្មីចំនួន៧០ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន១.២១២ក្បាល សត្វស្លាប់ចំនួន១៧១ក្បាល ព្យាបាលសត្វចំនួន២.៣២៣ក្បាល យកសំណាកទៅពិសោធន៍ចំនួន ៣៤៨ក្បាល ធ្វើឲ្យសន្លប់ចំនួន១៥៩ក្បាល ទម្លាក់សត្វល្អិតចំនួន៥៦០ក្បាល វះកាត់សាកសពសត្វចំនួន៩៥ក្បាល ដាក់លេខកូដចំនួន២៦ក្បាល ចាក់វ៉ាក់សាំងចំនួន៧៦១ក្បាល សាងសង់ទ្រុងសត្វថ្មីចំនួន២.៥៥០ម$^{២}$ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៧៥៤ម$^{២}$ ជួសជុលផ្លូវចំនួន១១៧.៧២៨ម$^{២}$ សាងសង់សំណង់ផ្សេងៗនិងសង់បង្គោលភ្លើងចំនួន២៧០ម$^{២}$ និង២៧ដើម តបណ្តាញភ្លើងចំនួន៣០០ម៉ែត្រ កាប់ឆ្ការអនាម័យព្រៃចំនួន២០៥.៨៦០ម$^{២}$ ដាំកូនឈើចំនួន១.៣៨៨ដើម បណ្តុះផ្កាលម្អចំនួន៤.៥៣១ដើម និងអប់រំផ្សព្វផ្សាយសិស្ស និស្សិតចំនួន៦.៤៦៥នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៥៤.៥១៧ក្បាល និងនាំចេញកូនស្វាក្តាមជំទង់ចំនួន២.៨៧២ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ការងារដាំឈើទូទាំងប្រទេសក្នុងឆ្នាំ២០១៥ មានការដាំឈើជាចម្ការថ្មី ការដាំឈើជាចម្ការពូជ ការដាំឈើបែបកសិ-រុក្ខកម្ម និងការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើដៃគូសហការ និងការដាំឈើដោយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចសម្រេចបានលើផ្ទៃដីទំហំ៤.៦៩០ហិកតា

- សហការជាមួយមូលនិធិបរិស្ថាន AEON រៀបចំកម្មវិធីដាំឈើនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ បានដាំកូនឈើក្នុងស្រុកចម្រុះប្រភេទចំនួន៧០.០០ដើម លើផ្ទៃដីទំហំ១,៥ហិកតា ដែលមានអ្នកចូលរួមសរុបចំនួន៧.០០០នាក់ ក្នុងនោះអ្នកទេសចរណ៍ជប៉ុនចំនួន៤៥០នាក់

- ក្រុមការងារស្រាវជ្រាវនិងកំណត់អត្តសញ្ញាណសត្វល្អិត L.invasa (Leptocybe invasa) បានចុះប្រមូលសំណាកដើមប្រេងខ្យល់តាមបណ្តាឡូត៍គំរូនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប។ ក្រុមការងារនឹងបន្តចុះប្រមូលសំណាកដើមប្រេងខ្យល់ នៅតាមបណ្តាឡូត៍គម្រូនៅខេត្តចំនួន៤ ទៀតគឺ ខេត្តតាកែវ កំពត ព្រះសីហនុ និងខេត្តកំពង់ស្ពឺ។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន៧ ដែលមានបរិមាណឈើកែច្នៃចំនួន ២១.៦៥៥ម$^{៣}$ ដើមចន្ទន៍ក្រស្នា(រុក្ខជាតិរស់)ចំនួន៧២ដើម ឈើចន្ទន៍ក្រស្នាកែច្នៃ(តុ)ចំនួន២០០គ.ក្រ ប្រេងចន្ទន៍ក្រស្នា

ក្រស្នាកែច្នៃចំនួន១០លីត្រ ឈើដើមអាកាស្យាកាត់ជាកង់ៗចំនួន៥.៤១០ស្ទែរ

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលិតផលឈើចំនួន៣ក្រុមហ៊ុន ដែលមានបរិមាណសរុប១.៥៧៣ម៣

- ផ្តល់ទិដ្ឋាការពន្យារអាជ្ញាប័ណ្ណនាំចេញចំណិតឈើអាកាស្យានិងប្រេងខ្យល់ចំនួន១ក្រុមហ៊ុន ដែលមានបរិមាណចំនួន៣.០០០តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន៦ ស្មើនឹង១៨៧សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន២១.៩៧៤ម៣ កម្ទេចឈើចំនួន៨៩៩តោន ដើមចន្ទន៍ក្រស្នាចំនួន២៥ដើម

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន២ ស្មើនឹង២៧សន្លឹក ដែលមានបរិមាណឈើអារឡាំងជ្រុងនិងផលិតផលបន្ទះក្តារចំនួន៨៧៣ម៣។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ឆ្នាំ២០១៥នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន១៩.២៨៨.២៣៥.០៥៨រៀល និងចំណូលពីសេវាសាធារណៈចំនួន៩.៨៩៨.៨៣៨.៥៩០រៀល និង៣១៥.៥៩០,១៣ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន២.១៨៩ករណី ដោយបញ្ជូនទៅតុលាការចំនួន១.៥៤៦ករណី និងពិន័យអន្តរការណ៍ចំនួន៦៤៣ករណី។ គួរកត់សម្គាល់ថា ក្នុងការចុះបំពេញបេសកកម្មការពារ និងអភិរក្សព្រៃធម្មជាតិនេះ មន្ត្រីរដ្ឋបាលព្រៃឈើមួយរូបបានពលីជីវិតដោយត្រូវជនល្មើសបាញ់សម្លាប់នៅខេត្តព្រះវិហារ

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៩៩៦ម៣ ឈើអារចំនួន៤.៧០៥ម៣ ឈើក្រាក់គ្រញូងចំនួន១១៣ម៣ និង៥.៧៩២គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៤.០១៨ក្បាលនិង២.៣៩៤គ.ក្រ អនុផលព្រៃឈើ សម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន២.៧០៩ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន៤៨៦គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ចុះពង្រឹងការអនុវត្តច្បាប់ចំនួន៣៨លើក នៅក្នុងខេត្តកោះកុង ព្រះសីហនុ កំពត កែប តាកែវ ត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ សៀមរាប និងខេត្តឧត្តរមានជ័យ ដោយបានចាត់វិធានការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើជាច្រើនករណី

- ចុះតាមដាន ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការងារពាក់ព័ន្ធការកាប់រានដីព្រៃចំនួន ២៧ករណី នៅក្នុងខេត្តសៀមរាប រតនគិរី ត្បូងឃ្មុំ ក្រចេះ និងខេត្តមណ្ឌលគិរី ដោយបានណែនាំឱ្យរដ្ឋបាលព្រៃឈើមូលដ្ឋានពង្រឹងការងារទប់ស្កាត់ និងបង្ក្រាបការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធិខុសច្បាប់

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន១.០២១ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានធ្វើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន២៤១ករណី

- ចុះពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មាននៅទីវាលជាក់ស្តែងចំនួន៤៩ករណីនៅក្នុងខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ និងខេត្តមណ្ឌលគិរី

- ចុះពិនិត្យនិងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើចំនួន១៧១ករណី នៅខណ្ឌរដ្ឋបាលព្រៃឈើត្បូងឃ្មុំ ក្រចេះ រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ សៀមរាប ព្រះវិហារ និងឧត្តរមានជ័យ ដោយបានធ្វើការកែលម្អនូវចំណុចខ្វះខាត

- តាមដាននិងជំរុញសំណុំរឿងបទល្មើសព្រៃឈើនៅតុលាការចំនួន១៩៩ករណី នៅខេត្តព្រៃវែង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី កំពង់ធំ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងបន្ទាយមានជ័យ ដោយបានណែនាំឱ្យខណ្ឌរដ្ឋបាលព្រៃឈើពាក់ព័ន្ធទាក់ទងតុលាការដើម្បីធ្វើការជំនុំជម្រះឱ្យបានឆាប់។

## ៥ ផ្នែកជលផល

### ៥.១ វារីវប្បកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន១៣.៤២៦តោន ស្មើ១៣៤,២៦% នៃផែនការ ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.១៤១តោន

- នេសាទគ្រួសារក្នុងដែននេសាទ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន៣៣៩.២៦៩តោន ស្មើ៩៦,៩៣% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៣.៣៣១តោន

- នេសាទគ្រួសារតាមវាលស្រែ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន១៣៥.២១០តោន ស្មើ៩០,១៤% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៤.៩១០តោន។

#### ៥.១.២ នេសាទសមុទ្រ

សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន១២០.៥០០តោន ស្មើ១០៩,៥៥% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន២៥០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន១៤៣.១៤១តោន ស្មើ៩៩,៤០% នៃផែនការ ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន២៣.០៨៦តោន

- ការចិញ្ចឹមក្រពើ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន២៩៨.៦៦៩ក្បាល ស្មើ១១៩,៤៧% នៃផែនការ ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៨៣.១៦៩ក្បាល

- ការភ្ញាស់កូនត្រីពូជ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួនប្រមាណ១៨០.៥០០.០០០កូន ស្មើ១០០,២៨% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួនប្រមាណ៦០.៥០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន៥០.៦០០តោន ស្មើ៦១,៧១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៩.៤០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ អនុវត្តបានចំនួន១០.១០០តោន ស្មើ១២៦,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.១០០តោន

- ការផលិតទឹកត្រី សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន៥៣.០០០.០០០លីត្រ ស្មើ១០៦% នៃផែនការ ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន១០.៥០០តោន ស្មើ៧០% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៨០០តោន

- ផលនេសាទកែច្នៃ សម្រាប់ឆ្នាំ២០១៥ អនុវត្តបានចំនួន៥.៥០០តោន ស្មើ១១០% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧០០តោន។

### ៥.៥ ការប្រយុទ្ធប្រឆាំងនឹងបទល្មើស

- សម្រាប់ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផលមានចំនួន៣.៩៧៤ករណី ក្នុងនោះបទល្មើសទឹកសាប ចំនួន៣.៨៣៣ករណី និងបទល្មើសសមុទ្រចំនួន១៤១ករណី

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន២៨០វគ្គ ដោយមានអ្នកចូលរួម ចំនួន១៧.៨៧៤នាក់ ក្នុងនោះស្ត្រីចំនួន៤.៥១១នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង១.៨៨៦.៨៦៧ ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៣៥.០០៦មាត់ បង្គោល/ចម្រឹងចំនួន១.២៣២.៥៨២ដើម ឧបករណ៍ឆក់ត្រីចំនួន ១.៤៨៧គ្រឿង សម្រាស់ចំនួន៦៤.១០០ម៉ែត្រក្រឡា របាំងព្រួលប្រវែង១៨.១៥៩ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្តុរ/ពោះ

រៀនថ្រូក)ចំនួន២.៥០១គ្រឿង លែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៣០០.៦៥៤គ.ក្រ និងលែងកូនត្រីឆ្តោចំនួន ៧៣២.២៥០កូន កូនត្រីរស់ចំនួន១.០៤១.០០០កូន និងលែងកូនត្រីប្រាចំនួន១.០៧០.៥០០ក្បាល

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់ បទល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរស់និងត្រីឆ្តោផងដែរ។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល សម្រាប់ឆ្នាំ២០១៥សរុបបានចំនួន៤.១៥០.៥៨៥.៧៥៧រៀល ស្មើ១១៦,៧៨% នៃ ផែនការ៣.៥៥៤.២៨១.២៥០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.០៥៩.៣៧៦.១៥៧រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗសរុបចំនួន១៣៩លើកនៅក្នុងប្រទេស និង១៤លើកនៅក្រៅប្រទេសដូចជា ប្រទេសអូស្ត្រាលី ជប៉ុន ចិន កូរ៉េ ថៃ ភូមា ឥណ្ឌូនេស៊ី អ៊ីតាលី និងឡាវ

- ធ្វើពិសោធន៍ចំនួន១១០ប្រភេទនៅ៧១០កន្លែង ធ្វើអង្កេតបានចំនួន១២ប្រភេទ ដោយបានសម្ភាសន៍ជាមួយ កសិករចំនួន៤.២០០នាក់

- ធ្វើទិវាស្រែបង្ហាញចំនួន១២កន្លែង ដែលមានកសិករចូលរួមចំនួន៨៦៥នាក់

- បើកវគ្គបណ្តុះបណ្តាលកសិករចំនួន២៩វគ្គ ដែលមានកសិករចូលរួមចំនួន១.០៥០នាក់

- ធ្វើការបែងចែកឯកសារបោះពុម្ពសរុបចំនួន១៦.៥៣០ច្បាប់

- បន្តអភិរក្សលើដំណាំចំនួន៣៣ប្រភេទ ដែលក្នុងនោះរួមមាន ស្រូវចំនួន៦.៦៨៨បញ្ជីក/សំណាក និងដំណាំ ផ្សេងៗចំនួន៣២ប្រភេទមាន១.២៥៥បញ្ជីក/សំណាក សរុបទាំងអស់ចំនួន៧.៩៤៣បញ្ជីក/សំណាក

- ប្រមូលពូជដំណាំថ្មីៗបានចំនួន៣២៤សំណាក ហើយបានយកពូជស្រូវចំនួន២១៧បញ្ជីកទៅរក្សាទុករយៈពេល យូរនៅធនាគារពន្ធុប្រទេសកូរ៉េ និងប្រមូលបន្ថែមពូជដំណាំចំនួន១១ប្រភេទ ក្នុងនោះ៣ប្រភេទថ្មី (ពោតសំឡី ស្រូវមីយែត និងដំឡូងបារាំង)

- ដឹកនាំនិស្សិតស្រាវជ្រាវនិងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន២៣នាក់ មកពីសាកលវិទ្យាល័យ ភូមិន្ទកសិកម្ម

- បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន១៦លើក ដែលមានអ្នកចូលរួមចំនួន៦០៤នាក់

- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន០៦លើក ដែលមានមន្ត្រីចូលរួមសរុប ចំនួន០៩នាក់ និងក្រៅប្រទេសចំនួន៤០លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីចូលរួមចំនួន៥៥នាក់ ហើយមន្ត្រី និងនិយោជិត សរុបចំនួន៤រូបបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតក្រៅប្រទេស

- ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh សម្រាប់ ឆ្នាំ២០១៥នេះ មានអ្នកចូលរួមសរុបចំនួន៤៣៩.០៩៥នាក់ គិតជាមធ្យមប្រមាណ១.២០៣នាក់ក្នុងមួយថ្ងៃ។

## ៧ ការងារអធិការកិច្ច

- បានចុះត្រួតពិនិត្យលើការងារគ្រប់គ្រងមន្ត្រីរាជការនៅតាមបណ្តាមន្ទីរកសិកម្ម អធិការដ្ឋានរដ្ឋបាលជលផល ព្រៃឈើ និងអង្គភាពមួយចំនួនក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្រាវជ្រាវករណីពាក្យបណ្តឹង ផ្សេងៗលើភាពមិនប្រក្រតីរបស់ក្រុមហ៊ុនមួយចំនួនសរុប២៥លើក

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រធ្វើអធិការកិច្ច និងក្រមសីលធម៌មន្ត្រីអធិការកិច្ចចំនួន២លើក ដោយមាន សិក្ខាកាមចូលរួមសរុប៥០រូប និងការចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីថ្នាក់អធិការកិច្ចនៅក្រៅប្រទេសចំនួន០១រូប។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារគ្រប់គ្រងសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន១១៥ក្រុមហ៊ុន សរុបចំនួន១.៩៣២មុខ

- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន១៧៥ក្រុមហ៊ុន ត្រូវជា២៦៧ករណី

- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន៣៨ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន៤២ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន៣៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន៣ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន៣៧៤សំណាក ក្នុងនោះរកឃើញសារធាតុលោហៈធ្ងន់លើសពីស្តង់ដារបមាណីយកំណត់ចំនួន៣សំណាក។

### ៨.៣ ការងារវគ្គបណ្តុះបណ្តាល អប់រំ

- រៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារនីតិកម្មកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៥ ដែលមានអ្នកចូលរួមចំនួន៧៧នាក់
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីនីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម ដែលមានអ្នកចូលរួមចំនួន១៤០នាក់ និងផ្សព្វផ្សាយនូវច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម នៅខេត្តត្បូងឃ្មុំ មណ្ឌលគិរី ព្រះសីហនុ កំពត កំពង់ស្ពឺ ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង រតនគិរី និងខេត្តស្ទឹងត្រែង ដែលមានសិក្ខាកាមចូលរួមចំនួន៦១៦នាក់
- បើកវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំរបស់អាស៊ានស្តីពីបទដ្ឋានគតិយុត្តក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ(BCA) សហការជាមួយអង្គការ GIZ ដែលមានអ្នកចូលរួមចំនួន១៨នាក់
- សហការជាមួយមន្ទីរកសិកម្មខេត្តរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម នៅខេត្តកំពង់ចាម មណ្ឌលគិរី កណ្តាល បន្ទាយមានជ័យ ស្វាយរៀង ដែលមានសិក្ខាកាមចូលរួមចំនួន២៨៥នាក់។

### ៨.៤ ការងារអនុវត្តច្បាប់

- ចាត់តាំងក្រុមការងារចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្ម ព្រមទាំងចុះធ្វើអធិការកិច្ចតាមដេប៉ូលក់ដុំ លក់រាយសម្ភារកសិកម្មនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តតាកែវ ត្បូងឃ្មុំ កំពង់ចាម មណ្ឌលគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន កំពង់ធំ និងខេត្តពោធិ៍សាត់
- ដកហូតឃាត់ទុកបណ្តោះអាសន្ន ថ្នាំកសិកម្មហាមឃាត់ (PARAQUAT) ចំនួន១៦ពីដុង (ក្នុង១ពីដុងចំណុះ១លីត្រ) និងឃាត់ទុកថ្នាំកម្ចាត់ស្មៅដែលនាំចូលដោយខុសច្បាប់របស់ក្រុមហ៊ុន KENVOS ចំនួន១០០ពីដុង (ក្នុង១ពីដុងចំណុះ១លីត្រ) វត្ថុតាងទាំងអស់ខាងលើបច្ចុប្បន្នរក្សាទុកនៅក្នុងមន្ទីរកសិកម្មខេត្តមណ្ឌលគិរី
- ចុះត្រួតពិនិត្យលើភាពមិនប្រក្រតីនៃការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនផ្សេងៗដែលបានធ្វើការចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានធ្វើការអនុវត្តវិធានការទណ្ឌកម្មលើក្រុមហ៊ុនចំនួន៧ និងដេប៉ូលក់រាយសម្ភារកសិកម្មចំនួន១០ ពិន័យអន្តរការណ៍ជាទឹកប្រាក់សរុបចំនួន៥២.២០០.០០០រៀល
- អនុវត្តវិធានការប្រមូលជីកន្ទុយបារីរបស់ក្រុមហ៊ុន ប៉ែន លឹម ត្រេឌីង បញ្ចូលឃ្លាំងរបស់មន្ទីរកសិកម្ម ខេត្តឧត្តរមានជ័យ និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការខេត្តសៀមរាប និងតុលាការខេត្តឧត្តរមានជ័យតាមនីតិវិធី។

## ៩ ផ្នែករដ្ឋបាល

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបណ្ណាញរក្សាទុកឯកសារ ការប្រើប្រាស់ប្រព័ន្ធអ៊ីម៉ែលនិងអ៊ិនធឺណែត ការចរាចរណ៍ឯកសារ និងការគ្រប់គ្រងឯកសាររដ្ឋបាលជូនមន្ត្រីរាជការក្រោមឱវាទក្រសួង
- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន៥.១១៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន៤.១១៦ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន១.៤២៧ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៩.១១២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន៦៤០ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ សរុប

ចំនួន៣០៥ច្បាប់ និងផ្តល់ទិដ្ឋាការបេសកកម្មមន្ត្រីមន្ទីរកសិកម្មរាជធានី ខេត្តចំនួន៥៤២ច្បាប់ សរុបមនុស្ស១៨៤០នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៩៨នាក់ នារីចំនួន១.៣៥៥នាក់ ស្មើនឹង២២%រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.០៨៩នាក់ ក្នុងនោះនារីចំនួន៧៨៥នាក់ ស្មើនឹង១៩%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦០៩នាក់ ក្នុងនោះនារីចំនួន៥៧០នាក់ ស្មើនឹង២២%
- ប្រកាសតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន២១៧នាក់ ក្នុងនោះស្ត្រីចំនួន១៤នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន១០នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន០៦នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៨៧នាក់
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៦៨នាក់ ក្នុងនោះបោះបង់ចោលការងារចំនួន២៣នាក់ សុំលាឈប់ពីការងារចំនួន២៨នាក់ និងមរណភាពចំនួន១៧នាក់
- ចេញច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន២៥នាក់ ច្បាប់ព្យាបាលជំងឺចំនួន៦៩នាក់ និងច្បាប់សម្រាកមាតុភាពចំនួន៣១នាក់
- ប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន២៧០នាក់
- ប្រកាសឲ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន១១០នាក់
- ប្រកាសដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈចំនួន១៨៧នាក់
- ចេញប្រកាសស្តីពីការអនុញ្ញាតឲ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន២០០នាក់ និងបុគ្គលិកអណ្តែតចំនួន៩៦៧នាក់
- បានប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដែលក្រសួងមុខងារសាធារណៈបែងចែកចំនួន២៧៧នាក់
- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៦២នាក់ ក្នុងនោះស្ត្រីចំនួន៥១នាក់៖ ថ្នាក់បណ្ឌិតចំនួន៣នាក់(ស្ត្រី១នាក់) ថ្នាក់អនុបណ្ឌិតចំនួន១១នាក់(ស្ត្រី៣នាក់) និងការបណ្តុះបណ្តាលរយៈពេលខ្លីចំនួន២៤៨នាក់(ស្ត្រី៥១នាក់)
- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន៧៦នាក់ ក្នុងនោះស្ត្រីចំនួន៣០នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំចំនួន៥គឺ៖ ១-កិច្ចប្រជុំរបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សហគមន៍កសិកម្ម និងកិច្ចប្រជុំលើកទី១៧របស់ក្រុមការងារបច្ចេកទេសអាស៊ានស្តីពីសហគមន៍កសិកម្ម ២-កិច្ចប្រជុំលើកទី៥ របស់ក្រុមការងារបច្ចេកទេសស្តីពីការអនុវត្តកសិកម្មល្អ ៣-កិច្ចប្រជុំថ្នាក់តំបន់និងអន្តរជាតិរបស់ក្រុមការងារបច្ចេកទេសក្រពើ នៅកម្ពុជា ៤-សិក្ខាសាលាស្តីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំលើកទី១៧នៃក្រុមជំនាញបច្ចេកទេសស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុលនៃថ្នាំពុលកសិកម្ម និង៥-សន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៥ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅខេត្តសៀមរាប
- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៤១៥រូប នៅប្រទេសចំនួន៣០
- អន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនផ្លូវការចំនួន២៣ច្បាប់ ពន្យារទិដ្ឋាការស្នាក់នៅជូនអ្នកបច្ចេកទេស និងជំនាញការបរទេសចំនួន២៣រូប

- អន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងអាទិភាព៥ឆ្នាំរំកិល ឆ្នាំ២០១៥-២០១៩ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងពិនិត្យលើឯកសារហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសស្តីពី Enhancing Capacity of Sanitary and Phytosanitary Arrangements to Facilitate Trade in the Greater Mekong Subregion រួចហើយ និងទទួលយកគម្រោងហិរញ្ញប្បទាននេះមកអនុវត្តបន្ត

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូ ទាំងអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងបណ្តាប្រទេសផ្តល់ជំនួយ ពាក់ព័ន្ធទាំងអស់ក្នុងវិស័យកសិកម្ម។

## ១២ ផ្នែកយេនឌ័រ និងកុមារ

### ១២.១- ការងារយេនឌ័រ:

- រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម(២០១៦-២០២០)និងបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥

- រៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មសម្រាប់រយៈពេល៥ឆ្នាំ (២០១៦-២០២០)

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុដល់សមាជិកក្រុមការងារយេនឌ័រ និងកុមារ ព្រមទាំងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធសរុបចំនួន២០នាក់ ក្នុងនោះស្ត្រី១៨នាក់ ដែលគាំទ្រដោយគម្រោង ADB7914។ សហការជាមួយអង្គការអភិវឌ្ឍន៍ហូឡង់ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលបន្តនៅថ្នាក់ខេត្តនិងសហគមន៍ និងវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងនារីភេទ(ស៊ីដ) ចំនួន០២វគ្គ ដល់មន្ត្រីកសិកម្មខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥៣នាក់ ក្នុងនោះស្ត្រីចំនួន២១នាក់ ខេត្តបាត់ដំបងដែលមានសិក្ខាកាមចូលរួមសរុបចំនួន៦៣នាក់ ក្នុងនោះស្ត្រីចំនួន១០នាក់

- ចូលរួមនិងជួយសម្របសម្រួលក្នុងដំណើរការរៀបចំវេទិកា កសិករស្ត្រីថ្នាក់ក្រោមជាតិចំនួន០៥ខេត្តគឺខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពត និងខេត្តព្រៃវែង ដែលមានកសិករជាស្ត្រីឆ្នើមចំនួន១០០នាក់ ក្នុងគម្រោងលើកកម្ពស់ស្ត្រីឲ្យក្លាយជាកសិករឆ្នើម របស់អង្គការ Oxfam

- ចូលរួមក្នុងកិច្ចពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពី សេចក្តីសង្កេតសន្និដ្ឋានអនុសាសន៍ទី១៥ និងទី២១ របស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិ

- ចូលរួមសិក្ខាសាលាស្តីពីការរៀបចំគោលការណ៍ណែនាំតាមបទដ្ឋានសម្រាប់បញ្ជ្រាបយេនឌ័រ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងផែនការថវិកា និងការអនុវត្តតាមវិស័យ នៅខេត្តកំពត

- រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារបញ្ជ្រាបយេនឌ័រឆ្នាំ២០១៥និងទិសដៅបន្តឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ។

### ១២.២- ការងារកុមារ:

- ធ្វើសិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាពលើគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្ម ដោយប្រើប្រាស់ថវិកាតាមកម្មវិធី

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីស្ថានភាពកុមារកសិកម្មនៅខេត្តតាកែវ ដោយប្រើប្រាស់ថវិកាតាមកម្មវិធី

- ផ្សព្វផ្សាយឲ្យអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍនិងការពារកុមារក្នុងវិស័យកសិកម្មនៅខេត្តកំពង់ឆ្នាំង

- ផ្សព្វផ្សាយពីគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅខេត្តកំពង់ឆ្នាំង ក្រចេះ ខេត្តព្រៃវែង កំពង់ធំ ស្វាយរៀង កំពត និងខេត្តឧត្តរមានជ័យ។

### ១២.៣- ការងារបណ្តុះបណ្តាល:

១២.៣.១- ការបណ្តុះបណ្តាលក្នុងប្រទេស

- ចូលរួមក្នុងពិធីដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម (២០១៥-២០១៨)

- ចូលរួមសិក្ខាសាលាស្តីពីរំញោចយេនឌ័រក្នុងបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយ ដែលរៀបចំដោយអង្គការ OXFAM

- ចូលរួមក្នុងកម្មវិធីសិក្ខាសាលាស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ។

១២.៣.២- ការបណ្តុះបណ្តាលក្រៅប្រទេស

- ចូលរួម Regional Workshop on Challenges and opportunities towards rural women's empowerment Agrarian transformations and the changing role of women in agriculture and food system and the Training for Gender Focal points នៅទីក្រុងបាងកក ប្រទេសថៃ

- ចូលរួមកម្មវិធី JENESYS 2015 ក្រោមប្រធានបទសកម្មភាពសង្គម និងវប្បធម៌មនុស្សពេញវ័យ នៅក្នុងទីក្រុង Tokyo ប្រទេសជប៉ុន

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍន៍សមត្ថភាពយេនឌ័រ នៅប្រទេសកូរ៉េ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការវាយតម្លៃ និងបទពិសោធន៍នានាក្នុងប្រទេសកម្ពុជា គំនិតផ្តួចផ្តើមរបស់អង្គការ USAID LEAF, Asia Pacific នៃភាពជាអ្នកដឹកនាំពាក់ព័ន្ធនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ នៅខេត្តត្រាត ប្រទេសថៃ។

## ១៣ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៣.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបចំនួន៩៩៤នាក់ (ស្ត្រី៣៥០នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន៧៥១នាក់(ស្ត្រី២៨២នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២៤៣នាក់(ស្ត្រី៦៨នាក់)។

និស្សិតសរុបមានការប្រែប្រួលថយចុះបន្តិចដោយសារនិស្សិតបានបញ្ចប់ការសិក្សាមានចំនួនច្រើនជាងនិស្សិតចូលថ្មី។ សាលាជាតិកសិកម្មព្រែកលៀបបានទទួលនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររងអាហារូបករណ៍)ឲ្យចូលរៀនសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ ជួសជុលអគារសិក្សាដេប៉ាតឺម៉ង់វិទ្យាសាស្ត្រជលផលនិងវិស្វកម្មកសិកម្មរួចរាល់ តភ្ជាប់ប្រព័ន្ធ Internet ចូលគ្រប់ដេប៉ាតឺម៉ង់និងការិយាល័យដើម្បីផ្តល់ឱកាសដល់និស្សិតសិក្សាស្រាវជ្រាវ និងចុះពិនិត្យតាមដានការងារនៅស្ថានីយ៍ពិសោធន៍នៅស្រុកត្រាំកក់ ខេត្តតាកែវ។ សហការជាមួយក្រុមហ៊ុនចិន Forword ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលលើជំនាញកសិកម្ម និងបញ្ជូនមន្ត្រី២នាក់ទៅទស្សនកិច្ចសិក្សានៅចិន។ បន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ដឹកនាំនិស្សិតពិសោធន៍ដាំបន្លែក្នុងបរិវេណសាលា ចុះជួយសហគមន៍ជំរុញការដាំកូនឈើនៅឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងសហការជាមួយ Winrork International រៀបចំសិក្ខាសាលាដែលមាននិស្សិតចូលរួម១០០នាក់។ បន្តចុះពិនិត្យការបោះបង្គោលព្រំប្រទល់ដីរបស់សាលាជាតិកសិកម្មព្រែកលៀប ស្ថិតនៅស្រុកថ្កូង ខេត្តកំពង់ស្ពឺ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន។

### ១៣.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន១.២១៨នាក់(ស្ត្រី៤៥៨នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្ត្រី៣៤១នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្ត្រី២៤១នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្ត្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្ត្រី៦៧នាក់) ថ្នាក់បរិញ្ញាបត្រចំនួន២១៧នាក់(ស្ត្រី៦៦នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា។ ដឹកនាំនិស្សិតផ្នែកអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ជំនាញដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ

ក្សេត្រសាស្ត្រ ចុះទស្សនកិច្ចសិក្សានៅខេត្តកំពត ព្រះសីហនុ ពោធិ៍សាត់ បាត់ដំបង មណ្ឌលគិរី កំពង់ស្ពឺ សៀមរាប និងខេត្តប៉ៃលិន។ បន្តរៀបចំការស្រាវជ្រាវផលិតកម្មដំណាំស្រូវរបស់គម្រោង HEQCIP។ ចូលរួមរៀបចំបង្កើតសហគមន៍កសិកម្មមាន់សមានជ័យ នៅឃុំមេសជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ចុះផ្សព្វផ្សាយពីការធ្វើគណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម។ ផ្តល់ពូជជ្រូកជូនកសិករក្រីក្រនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានចំនួន១៨គ្រួសារ និងបើកវគ្គបណ្តុះបណ្តាលស្តីពីប្រពលវប្បកម្មដំណាំស្រូវ នៅឃុំតុងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម និងឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។

**១៣.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន៤.០៧៩នាក់(ស្រី១.២២៤នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានសហការជាមួយអង្គការ OXFAM America ក្នុងការបើកសិក្ខាសាលាបង្ហាញពីលទ្ធផលនៃការធ្វើតេស្តឧបករណ៍ស្ទូងស្រូវ ជូនដល់កសិករមកពីខេត្តតាកែវ និងនិស្សិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សហការជាមួយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលធ្វើសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រលើប្រធានបទ បញ្ហាប្រឈមនិងដំណោះស្រាយ រយៈពេល៣ថ្ងៃនៅខេត្តកំពង់ចាម ជូនដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់។ សាកលវិទ្យាល័យបានសហការជាមួយ KOPIA កម្ពុជា រៀបចំកិច្ចប្រជុំវាយតម្លៃគម្រោងចិញ្ចឹមមាន់របស់កសិករនិងប្រគល់គោយន្តចំនួន៣គ្រឿងជូនកសិករ នៅភូមិកំពង់ពោធិ៍ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល។ សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាស្ត្រាចារ្យសាកលវិទ្យាល័យណាហ្គូយ៉ានៃប្រទេសជប៉ុនចំនួន១០នាក់ នឹងដឹកនាំនិស្សិតជប៉ុនចំនួន៣៧នាក់ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន៣៧នាក់ចុះធ្វើកម្មសិក្សានៅខេត្តកណ្តាល និងខេត្តកំពង់ចាមចំនួន១សប្តាហ៍។ សាកលវិទ្យាល័យបានទទួលនិស្សិតនិងសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Handong Global នៃប្រទេសកូរ៉េ មកធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១០នាក់។ ប្រជុំពិភាក្សាជាមួយប្រតិភូនៃសាកលវិទ្យាល័យ Yunnan នៃប្រទេសចិន ស្តីពីកិច្ចសហប្រតិបត្តិការលើការងារបណ្តុះបណ្តាលនិងស្រាវជ្រាវផ្នែកកសិកម្ម។ សាកលវិទ្យាល័យបានបញ្ជូនមន្ត្រីសាស្ត្រាចារ្យសរុបចំនួន៨នាក់ ទៅចូលរួមសិក្ខាសាលានិងប្រជុំការងារនៅប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសជប៉ុន។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

សម្រាប់ឆ្នាំ២០១៥នេះ ការងារប្រមូលផលស្រូវរដូវវស្សាត្រូវបានវាយតម្លៃថាអនុវត្តលឿនជាងឆ្នាំមុន ដែលមកទល់ពេលនេះការប្រមូលផលសម្រេចបានប្រមាណ៨៩,៣០% (ឆ្នាំមុនសម្រេចបានតែ៨៨,៦២%ប៉ុណ្ណោះ)។ ខេត្តចំនួន១០ បានបញ្ចប់ការប្រមូលផលស្រូវរដូវវស្សារួចរាល់ហើយ។ ដោយឡែក ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ ទោះបីជួបប្រទះឥទ្ធិពលអវិជ្ជមានបណ្តាលមកពីគ្រោះរាំងស្ងួតកាលពីរដូវវស្សាយ៉ាងណាក៏ដោយ ក៏ការដាំដុះសម្រេចបានចំនួន ៤១៩.៩៥៥ហិកតា ស្មើនឹង១០០,៥៤% នៃផែនការ៤១៧.៣២៥ហិកតា លឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យខិតខំថែទាំដំណាំស្រូវរដូវប្រាំង ដោយយកចិត្តទុកដាក់ការគ្រប់គ្រងនិងថែរក្សាទឹកទុកឲ្យបានគត់មត់ ក៏ដូចជាការថែទាំដំណាំផ្សេងៗ ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់ពីលទ្ធភាពនៅកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់។ ជាពិសេសការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធានការថែរក្សាទឹកទុក។ តាម

លទ្ធផលនៃការវាយតម្លៃ និងបូកសរុបបឋមនៃការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ និងវិធានការជំរុញការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ បានបង្ហាញថា ផ្ទៃដីប្រមូលផលសរុបអាចទទួលបានចំនួន២.៩៩៦.២៥៩ហិកតា (រដូវវស្សា២.៩៣៦.១៩៧ហិកតា+រដូវប្រាំង៥៦០.០៦២ហិកតា=២.៩៩៦.២៥៩ហិកតា) គឺតិចជាងឆ្នាំមុនចំនួន៣២.៥៧៧ហិកតា (ឆ្នាំមុន៣,០២៨លានហិកតា)។ បរិមាណផលប៉ាន់ស្មានសរុប៩.២២៧.០២១តោន (ឆ្នាំមុន៩,៣២លានតោន) និងទិន្នផលមធ្យមទូទាំងប្រទេស៣,០៨០តោន/ហិកតា (ឆ្នាំមុន៣,០៧៩តោន/ហិកតា)។ ដូច្នេះបើគិតពីតុល្យភាពស្បៀងរវាងសេចក្តីត្រូវការ និងបរិមាណផលស្រូវទទួលបានឃើញថាអាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង៤,៥លានតោន (ឆ្នាំមុនសម្រេចបាន៤,៧លានតោន) និងគិតជាអង្ករប្រមាណជាង២,៩១លានតោន (ឆ្នាំមុនជាង៣,០១លានតោន) សម្រាប់នាំចេញ។

ដោយឡែក បរិមាណអង្ករនាំចេញសរុបក្នុងឆ្នាំ២០១៥មានចំនួន៥៣៨.៣៩៦តោន ដែលបរិមាណនេះមានកំណើនប្រមាណ៣៩,១% ធៀបនឹងបរិមាណនាំចេញក្នុងឆ្នាំ២០១៤។ ពិតមែនតែសន្ទុះនៃការនាំចេញអង្ករក្នុងឆ្នាំ២០១៥នេះមានការកើនឡើងជិត៥៤% ប៉ុន្តែពុំទាន់បានសម្រេចតាមទិសដៅនៃផែនការដែលបានកំណត់ក្នុងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលនៅឡើយទេ។ ទោះយ៉ាងណាក៏យើងនៅតែមានមោទនភាពក្នុងនាមជាប្រទេសនាំចេញអង្ករដ៏ក្មេងខ្ចីមួយនៅក្នុងតំបន់ និងជាប្រទេសដែលស្ថិតនៅក្នុងចន្លោះប្រទេសពីរដែលជាអ្នកនាំអង្ករចេញដ៏ធំបំផុតលើពិភពលោក។ ក្នុងបរិការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងខិតខំបន្តទៀតដោយប្រមូលយកបទពិសោធន៍និងកេរ្តិ៍ឈ្មោះដែលបានទទួលមកដល់ពេលនេះដើម្បីទទួលបានជោគជ័យ។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយរហូតដល់មន្ត្រីជំនាញមួយចំនួនទទួលរងនូវការគំរាមកំហែង និងគ្រោះថ្នាក់ដល់អាយុជីវិតក៏មាន។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំសារាចរណែនាំបន្ថែមទៀតអំពីការការពារ ទប់ស្កាត់ភ្លើងព្រៃនៅក្នុងរដូវប្រាំងនេះ។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៥នេះ។

## IV- ទិសដៅអនុវត្តបន្ត

យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល នៅក្នុងឆ្នាំ២០១៦ខាងមុខនេះ ព្រះរាជាណាចក្រកម្ពុជានឹងទទួលរងនូវបាតុភូត El Nino (ក្តៅ) រហូតដល់ចុងខែមិថុនា។ ឥទ្ធិពលនៃបាតុភូត El Nino នេះអាចនឹងបង្កឲ្យរដូវវស្សាមកដល់យឺតនៅដើមរដូវវស្សាមានភ្លៀងធ្លាក់តិច មានបាតុភូតផ្គររន្ទះ ខ្យល់កន្ត្រាក់កើតឡើងច្រើន កម្រិតសីតុណ្ហភាពអតិបរមាកើនឡើងអាកាសធាតុក្តៅហួតហែង។ល។ ស្ថានភាពអាកាសធាតុបែបនេះនឹងកើតមានចាប់ពីខែកុម្ភៈ រហូតដល់ចុងខែមិថុនា ឆ្នាំ២០១៦។ កត្តាទាំងនេះអាចនឹងធ្វើឲ្យកម្ពុជារបស់យើងប្រឈមនឹងកង្វះខាតទឹក សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅតាមតំបន់មួយចំនួន ហើយរហូតដល់ពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៦ ទើបបាតុភូតថ្មី La Nina (ត្រជាក់) មានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជាវិញ ហើយភ្លៀងក៏នឹងចាប់ផ្តើមធ្លាក់នាពេលនោះផងដែរ។

### ១ ផ្នែកដាំដុះ :

យោងលើស្ថានភាពអាកាសធាតុដូចបានព្យាករណ៍ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់វិធានការផ្សព្វផ្សាយដល់គ្រប់អង្គភាពក្រោមឱវាទទាំងអស់ដើម្បីអនុវត្តសារាចរណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ដែលបានធ្វើការណែនាំដូចតទៅៈ

១-ការងារបង្កបង្កើនផលស្រូវប្រាំងក្នុងឆ្នាំនេះ(២០១៥-២០១៦) គឺអាចធ្វើបានតែ១ដងប៉ុណ្ណោះ ដោយមិនអាចធ្វើ

ស្រូវប្រាំងលើកទី២បានទេ ទោះបីជាទឹកតាមបណ្តាអាងដែលបានរក្សាទុកនិងកន្លែងមួយចំនួនដែលមានទឹកធម្មជាតិក៏ដោយ គួរតែប្រើរក្សាទឹកទាំងនោះសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងការដាំដំណាំរួមផ្សំផ្សេងទៀតក្រៅពីស្រូវ។

២-ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមចាត់វិធានការថែរក្សាទឹកទុកឲ្យបានល្អ ដើម្បីផ្គត់ផ្គង់សម្រាប់តែការប្រើប្រាស់ប្រចាំថ្ងៃតែប៉ុណ្ណោះរហូតដល់ពេលមានភ្លៀងធ្លាក់។

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវវស្សានេះឱ្យបានសម្រេចតាមផែនការ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីស្តារការដាំដុះឡើងវិញឱ្យបានទាន់ពេលវេលានៅតំបន់ដែលទទួលរងការខូចខាតដោយគ្រោះរាំងស្ងួត ព្រមទាំងត្រៀមបម្រុងគ្រាប់ពូជស្រូវសម្រាប់ផ្តល់ជូនកសិករក្រីក្រដែលពុំមានលទ្ធភាពទិញគ្រាប់ពូជជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាលឬស្រូវកណ្តាលដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងកសិករ ម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកទិញ-លក់ស្រូវអង្ករមានវិធានការជាបន្ទាន់ដោយប្រើប្រាស់កម្លាំងសរុប ដើម្បីជំរុញការទប់ស្កាត់ ការបាត់បង់ទាំងបរិមាណនិងគុណភាពស្រូវអង្ករនៅពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករឱ្យទទួលបានជោគជ័យនិងជំរុញការដាំដុះស្រូវប្រាំងឱ្យទទួលបានលទ្ធផលល្អ ក្នុងន័យធានាបាននូវសន្តិសុខស្បៀងនិង ការកាត់បន្ថយភាពក្រីក្រ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខ័ណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

**២ ផ្នែកផលិតកម្មនិងបសុពេទ្យសាស្ត្រ :**

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺផ្តកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ :**

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធ-សាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤ ផ្នែកជលផល :**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- បន្តចាត់វិធានការក្នុងការទប់ស្កាត់ និងលុបបំបាត់ការចិញ្ចឹមត្រីឆ្តោនិងត្រីរ៉ស់ ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិឲ្យបានហ្មត់ចត់ប្រកបដោយប្រសិទ្ធភាពខ្ពស់

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្កា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- រៀបចំក្រុមការងារដើម្បីទទួលខុសត្រូវក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ធ្វើពាណិជ្ជកម្មក្នុងការត្រៀមលក្ខណៈសមាហរណកម្មចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វ៉េង សាខុន**